# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ.........សហវ.....

# ប្រកាសអន្តរក្រសួង
## ស្តីពី
## ការផ្តល់សេវាសាធារណៈដោយក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**រដ្ឋមន្ត្រី ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីការកែសម្រួល និងតែងតាំងសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៦ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣៩៧/០១ ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការងារ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥១៦/០០៧ ចុះថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០១៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហជីព



ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom , khan Daun Penh, Phnom Penh, CAMBODIA.
ទូរសព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax : 855-23-427 798

- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៧៥ អនក្រ.បក ចុះថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០១៧ ស្តីពីការកែសម្រួលអនុក្រឹត្យលេខ ៤៨៨ ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ២៨៣ អនក្រ. បក ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០១៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញអនុក្រឹត្យលេខ ៨២ អនក្រ. បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្តីពីបទបញ្ញត្តិទូទៅនៃគណនេយ្យសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ១៩០ អនក្រ.បក ចុះថ្ងៃទី១៧ ខែសីហា ឆ្នាំ២០១១ ស្តីពីការគ្រប់គ្រងលើការបញ្ជូនពលករខ្មែរទៅធ្វើការនៅបរទេសតាមរយៈទីភ្នាក់ងារជ្រើសរើសឯកជន
- បានឃើញអនុក្រឹត្យលេខ ៤០ អនក្រ.បក ចុះថ្ងៃទី៣១ ខែមីនា ឆ្នាំ២០១៥ ស្តីពីការកែសម្រួលតារាងពន្ធតែមប្រិ៍សារពើពន្ធ
- បានឃើញអនុក្រឹត្យលេខ ៧២ អនក្រ.បក ចុះថ្ងៃទី៧ ខែមិថុនា ឆ្នាំ២០១៨ ស្តីពីការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ
- បានឃើញបទបញ្ជាលេខ ០៤ បប. ចុះថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០០៦ របស់រាជរដ្ឋាភិបាល ស្តីពីការពង្រឹងការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ
- បានឃើញលិខិតជូនដំណឹងលេខ ១៣៣ សជណ.អវ ចុះថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០១៦ របស់ទីស្តីការគណៈរដ្ឋមន្ត្រី
- ប្រកាសរួមលេខ ០៩ សកអ/៩៤ ចុះថ្ងៃទី១៩ ខែមករា ឆ្នាំ១៩៩៤ របស់អតីតក្រសួងសង្គមកិច្ច ការងារ និងអតីតយុទ្ធជន និងក្រសួងសុខាភិបាល ស្តីពីការពិនិត្យកាយសម្បទាសំរាប់ជនកម្ពុជា និងជនបរទេស ដែលមកប្រកបមុខរបរនៅព្រះរាជាណាចក្រកម្ពុជា
- ប្រកាសរួមលេខ ៣៣០ ស.ក.ប.យ ចុះថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០០០ របស់អតីតក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា និង ក្រសួងសុខាភិបាល ស្តីពីការរៀបចំគិលានដ្ឋានសហគ្រាស
- ប្រកាសរួមលេខ ១៣៩ សកបយ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០០១ របស់អតីតក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា និងក្រសួងសុខាភិបាល ស្តីពីល័ក្ខខ័ណ្ឌ និងបេសកកម្ម សេវាពេទ្យសហគ្រាស
- យោងតាមការចាំបាច់របស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## សម្រេច

**ប្រការ១ .-**

អនុញ្ញាតឱ្យក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ អនុវត្តការប្រមូលចំណូលពីកម្រៃសេវាសាធារណៈ សម្រាប់ជាគុណប្រយោជន៍ដល់ថវិកាជាតិ។

**ប្រការ២ .-**

សេវាសាធារណៈដែលផ្តល់ដោយក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ត្រូវបានរៀបចំជាកម្រងសេវាសាធារណៈ ដែលមានរាយលម្អិតអំពីប្រភេទសេវា តម្លៃសេវា រយៈពេលអតិបរមានៃការផ្តល់សេវា និងសុពលភាពទៅតាមប្រភេទសេវាសាធារណៈនីមួយៗ ដូចមានចែងក្នុងឧបសម្ព័ន្ធ១ និងឧបសម្ព័ន្ធ២ ភ្ជាប់នឹងប្រកាសអន្តរក្រសួងនេះ។

**ប្រការ៣ .-**

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ត្រូវផ្សព្វផ្សាយជាសាធារណៈ ជាពិសេសនៅកន្លែងផ្តល់សេវាសាធារណៈ ត្រូវបិទផ្សាយប្រកាសអន្តរក្រសួង និងកម្រងសេវាសាធារណៈដែលរួមមានឧបសម្ព័ន្ធនៃប្រកាសអន្តរក្រសួងនេះ ព្រមទាំងនីតិវិធី និងលក្ខខណ្ឌសម្រាប់ការផ្តល់សេវាដែលមានការពាក់ព័ន្ធ។

នៅកន្លែងផ្តល់សេវាសាធារណៈ ត្រូវរៀបចំឱ្យមានកន្លែងទទួលបណ្តឹងតវ៉ា ដែលអាចកើតមានឡើងជាយថាហេតុ ជាពិសេសក្នុងករណីមានការអនុវត្តខុសពីស្តង់ដារសេវា ឬ មានការយកកម្រៃលើសការកំណត់ ឬ ការផ្តល់សេវាសាធារណៈមានការយឺតយ៉ាវហួសរយៈពេលអតិបរមាដែលបានកំណត់ជាដើម។

ការទទួលបណ្តឹងតវ៉ារបស់អតិថិជន ត្រូវមានការបើកទូលាយដោយមានដាក់ប្រអប់សំបុត្រ លេខទូរស័ព្ទ សារអេឡិចត្រូនិក ដែលផ្តល់ឱកាសឱ្យអតិថិជនអាចធ្វើទំនាក់ទំនង ឬ ប្តឹងទៅខុទ្ទកាល័យរដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ឬ អង្គភាពប្រឆាំងអំពើពុករលួយផងដែរ។ ក្នុងករណីមានបណ្តឹងតវ៉ា ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈត្រូវពិនិត្យលទ្ធភាពដោះស្រាយឱ្យបានឆាប់ ឬ ដោះស្រាយក្នុងរយៈពេលយ៉ាងយូរ ៧(ប្រាំពីរ)ថ្ងៃ នៃថ្ងៃធ្វើការ ដោយគិតចាប់ពីកាលបរិច្ឆេទទទួលបណ្តឹងតវ៉ាពីសាមីជន។

**ប្រការ៤ .-**

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ត្រូវកំណត់ទីតាំងជាក់លាក់ និងមានមន្ត្រីប្រចាំការដែលមានលក្ខណៈជាច្រកចេញចូលតែមួយនៅទីតាំងដែលបានកំណត់ ដើម្បីទទួលបម្រើសេវាជូនអតិថិជនឱ្យបានទាន់ពេលវេលា តាមការកំណត់។ ទន្ទឹមនឹងនេះ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ត្រូវពង្រឹង និងពង្រីកប្រព័ន្ធស្វ័យប្រវត្តិកម្ម (Online System) សម្រាប់ការផ្តល់សេវាសាធារណៈឱ្យកាន់តែមានភាពងាយស្រួល មានតម្លាភាព និងមានប្រសិទ្ធភាព។

ដោយឡែកចំពោះការផ្តល់សេវាសាធារណៈរបស់មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈរាជធានី ខេត្ត ត្រូវបន្តអនុវត្តតាមយន្តការ និងនីតិវិធីដែលមានស្រាប់រហូតដល់មានការប្រមូលផ្តុំសេវាឱ្យធ្វើឡើងតាមរយៈយន្តការច្រកចេញចូលតែមួយរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។

**ប្រការ៥ .-**

រាល់ការទទួលប្រាក់ចំណូលដោយផ្ទាល់ជាសាច់ប្រាក់ ឬ ជាមូលប្បទានប័ត្រ លើការប្រមូលចំណូលពីកម្រៃសេវាសាធារណៈ ត្រូវប្រើប្រាស់បង្កាន់ដៃបង់ប្រាក់ដែលបើកផ្តល់ដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្របតាមប្រកាសលេខ ២៧២ សហវ.ប្រក ចុះថ្ងៃទី១៧ ខែមីនា ឆ្នាំ២០១១ ស្តីពីការដាក់ឱ្យប្រើប្រាស់បង្កាន់ដៃបង់ប្រាក់ និងសារាចរណែនាំលេខ ០០៥ សហវ ចុះថ្ងៃទី១៧ ខែមីនា ឆ្នាំ២០១១ ស្តីពីការគ្រប់គ្រងបង្កាន់ដៃបង់ប្រាក់របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

**ប្រការ៦ .-**

ការកែសម្រួលភារកិច្ចលើការផ្តល់សេវាសាធារណៈ រវាងរដ្ឋបាលកណ្តាលក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈរាជធានី ខេត្តត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ។ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ត្រូវផ្ញើប្រកាសនេះចំនួនមួយច្បាប់ជូនក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដើម្បីជ្រាបជាព័ត៌មាន និងតាមដានការអនុវត្ត។

**ប្រការ៧ .-**

រដ្ឋបាលកណ្តាលក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈរាជធានី ខេត្ត ត្រូវរៀបចំគម្រោងចំណូលថវិកាប្រចាំឆ្នាំដាច់ដោយឡែកពីគ្នា ដោយមានមូលដ្ឋានគ្រោងគិតចំណូលច្បាស់លាស់ និងគ្រោងចំណូលលម្អិតទៅតាមប្រភេទសេវាសាធារណៈនីមួយៗ យោងតាមភារកិច្ចប្រមូលចំណូលរៀងៗខ្លួន។

នៅពេលអនុវត្តចំណូល រដ្ឋបាលកណ្តាលក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈរាជធានី ខេត្ត ត្រូវទទួលខុសត្រូវប្រាក់កាសលើប្រាក់ចំណូលប្រមូលបាន បង់ប្រាក់ចំណូល និងធ្វើសលាកប័ត្រចំណូលថវិកាជាតិ ព្រមទាំងចុះកិច្ចបញ្ជិកាគណនេយ្យស្តីពីកិច្ចប្រតិបត្តិការចំណូល និងកត់ត្រាតាមដានប្រាក់ចំណូលនៅក្នុងជំពូក គណនី អនុគណនី នៃមាតិកាចំណូលថវិកា។

**ប្រការ៨ .-**

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈត្រូវធ្វើរបាយការណ៍ស្តីពីការអនុវត្តចំណូលប្រចាំខែ និងប្រចាំឆ្នាំផ្ញើមកក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ឱ្យបានមុនថ្ងៃទី១០ នៃខែបន្ទាប់ សម្រាប់របាយការណ៍ប្រចាំខែ និងឱ្យបានមុនថ្ងៃទី១៥ ខែមករា នៃឆ្នាំបន្ទាប់ សម្រាប់របាយការណ៍ប្រចាំឆ្នាំ។

មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈរាជធានី ខេត្ត ត្រូវធ្វើរបាយការណ៍ស្តីពីការអនុវត្តចំណូលប្រចាំខែ និងប្រចាំឆ្នាំ ផ្ញើជូនក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុរាជធានី ខេត្ត ឱ្យបានមុនថ្ងៃទី១០ នៃខែបន្ទាប់ សម្រាប់របាយការណ៍ប្រចាំខែ និងឱ្យបានមុនថ្ងៃទី១៥ ខែមករា នៃឆ្នាំបន្ទាប់ សម្រាប់របាយការណ៍ប្រចាំឆ្នាំ។

**ប្រការ៩ .-**

កម្រងសេវាសាធារណៈ ដូចមានចែងក្នុងឧបសម្ព័ន្ធនៃប្រកាសអន្តរក្រសួងនេះ អាចកែប្រែបានតាមការចាំបាច់ តាមរយៈប្រកាសអន្តរក្រសួងរវាងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងរដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ។

**ប្រការ១០ .-**

ត្រូវបាននិរាករណ៍ប្រកាសរួមលេខ ១០០៩ សហវ.ប្រក ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០១២ ស្តីពីការផ្តល់សេវាសាធារណៈរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ។

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសអន្តរក្រសួងនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ១១ .-**

អគ្គលេខាធិការ នាយកខុទ្ទកាល័យ អគ្គនាយក អគ្គាធិការ ប្រធាននាយកដ្ឋាន និងប្រធានអង្គភាពពាក់ព័ន្ធ នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវទទួលបន្ទុកអនុវត្តប្រកាសអន្តរក្រសួងនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃទី ០១ ខែ សីហា ឆ្នាំ២០១៨ តទៅ។

ថ្ងៃ ព្រហស្បតិ៍ ៦កើត ខែ ទុតិយាសាឍ ឆ្នាំច សំរឹទ្ធិស័ក ព.ស ២៥៦២

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែ កក្កដា ឆ្នាំ២០១៨

**ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី**

**ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

**រដ្ឋមន្ត្រី**

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

**អ៊ិត សំហេង**

កន្លែងទទួល :

- ទីស្តីការគណៈរដ្ឋមន្ត្រី
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- អាជ្ញាធរសវនកម្មជាតិ
- អង្គភាពប្រឆាំងអំពើពុករលួយ
- សាលារាជធានី ខេត្ត
- ដូចប្រការ ១១
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

# ឧបសម្ព័ន្ធ១

## ការផ្តល់សេវាសាធារណៈដោយរដ្ឋបាលកណ្តាលក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

## ភ្ជាប់នឹងប្រកាសអន្តរក្រសួងលេខ ៧១៤ សហវ.ប្រក ចុះថ្ងៃទី ១៩ ខែ កក្កដា ឆ្នាំ២០១៨

| លេខរៀងចំនួនសេវា | | បរិយាយ | តម្លៃឯកតានៃសេវា (រៀល) | រយៈពេលអតិបរមាសម្រាប់ការផ្តល់សេវា (ថ្ងៃធ្វើការ) | សុពលភាព |
|---|---|---|---|---|---|
| I. សេវាសាធារណៈផ្តល់ដោយនាយកដ្ឋានពេទ្យការងារ | | | | | |
| | 1 | ការពិនិត្យកាយសម្បទាកម្មករ និយោជិតខ្មែរ មុនចូលបម្រើការងារនៅតាមសហគ្រាស-គ្រឹះស្ថាន | | | |
| 1 | 1.1 | ពិនិត្យនៅនាយកដ្ឋានពេទ្យការងារ | 20 000 | 7ថ្ងៃ | |
| 2 | 1.2 | ចុះទៅពិនិត្យដល់សហគ្រាស គ្រឹះស្ថាន នៅក្នុងរាជធានីភ្នំពេញ (តាមការស្នើសុំរបស់សហគ្រាស-គ្រឹះស្ថាន) | 24 000 | 10ថ្ងៃ | |
| 3 | 1.3 | ចុះទៅពិនិត្យដល់សហគ្រាស គ្រឹះស្ថាន នៅតាមបណ្តាលខេត្ត (តាមការស្នើសុំរបស់សហគ្រាស-គ្រឹះស្ថាន) | 28 000 | 10ថ្ងៃ | |
| | 2 | ការពិនិត្យកាយសម្បទាកម្មករ និយោជិតបរទេស មុនចូលបម្រើការងារនៅតាមសហគ្រាស-គ្រឹះស្ថាន | | | |
| 4 | 2.1 | ពិនិត្យនៅនាយកដ្ឋានពេទ្យការងារ | 100 000 | 7ថ្ងៃ | |
| 5 | 2.2 | ចុះទៅពិនិត្យដល់សហគ្រាស គ្រឹះស្ថាន នៅក្នុងរាជធានីភ្នំពេញ (តាមការស្នើសុំរបស់សហគ្រាស-គ្រឹះស្ថាន) | 110 000 | 10ថ្ងៃ | |
| 6 | 2.3 | ចុះទៅពិនិត្យដល់សហគ្រាស គ្រឹះស្ថាន នៅតាមបណ្តាលខេត្ត (តាមការស្នើសុំរបស់សហគ្រាស-គ្រឹះស្ថាន) | 120 000 | 10ថ្ងៃ | |
| | 3 | ការពិនិត្យសុខភាពពលករខ្មែរទៅបម្រើការងារនៅបរទេស និងពិនិត្យសុខភាព (តាមការស្នើសុំ) | | | |
| 7 | 3.1 | ការធានាសេវាបញ្ជូនពលករ (សេវាបកប្រែឯកសារជាភាសាអង់គ្លេស) | 40 000 | 5ថ្ងៃ | |
| 8 | 3.2 | សេវាគ្រូពេទ្យពិនិត្យ (ត្រចៀក ច្រមុះ បំពង់ក ភ្នែក សួត បេះដូង កាយសម្បទា) | 10 000 | 5ថ្ងៃ | |
| 9 | 3.3 | សេវាថតវិទ្យុសាស្ត្រ | 18 000 | 5ថ្ងៃ | |

| លេខរៀងចំនួនសេវា | បរិយាយ | | តម្លៃឯកតានៃសេវា (រៀល) | រយៈពេលអតិបរមាសម្រាប់ការផ្តល់សេវា (ថ្ងៃធ្វើការ) | សុពលភាព |
|---|---|---|---|---|---|
| | 4 | សេវាមន្ទីរពិសោធន៍ | | | |
| | 4.1 | ផ្នែកទី1 : ពិនិត្យឈាម | | | |
| 10 | | - Hematocrite | 4 000 | 2ថ្ងៃ | |
| 11 | | - Hematology test (Hg+Vs) | 10 000 | 2ថ្ងៃ | |
| 12 | | - Blood Group | 4 000 | 2ថ្ងៃ | |
| 13 | | - Glucose | 8 000 | 2ថ្ងៃ | |
| 14 | | - Total Cholesterol | 8 000 | 2ថ្ងៃ | |
| 15 | | - HDL-Cholesterol | 7 000 | 2ថ្ងៃ | |
| 16 | | - LDL-Cholesterol | 9 000 | 2ថ្ងៃ | |
| 17 | | - Triglyceride | 6 000 | 2ថ្ងៃ | |
| 18 | | - Calcium | 5 000 | 2ថ្ងៃ | |
| 19 | | - Uric Acid | 5 000 | 2ថ្ងៃ | |
| 20 | | - Albumin | 5 000 | 2ថ្ងៃ | |
| 21 | | - Creatinine | 6 000 | 2ថ្ងៃ | |
| 22 | | - Blood Urea | 6 000 | 2ថ្ងៃ | |

| លេខរៀង ចំនួនសេវា | បរិយាយ | | តម្លៃឯកតានៃសេវា (រៀល) | រយៈពេលអតិបរមា សម្រាប់ការផ្តល់សេវា (ថ្ងៃធ្វើការ) | សុពលភាព |
|---|---|---|---|---|---|
| 23 | | - Serum Iron | 7 000 | 2ថ្ងៃ | |
| 24 | | - HIV Antibody (Elisa) | 25 000 | 2ថ្ងៃ | |
| 25 | | - HBs Ag (Elisa) | 18 000 | 2ថ្ងៃ | |
| 26 | | - HBs Ab | 20 000 | 2ថ្ងៃ | |
| 27 | | - HCV Ab | 34 000 | 2ថ្ងៃ | |
| 28 | | - HAV IgM | 40 000 | 2ថ្ងៃ | |
| 29 | | - HAV IgG | 40 000 | 2ថ្ងៃ | |
| 30 | | - GOT | 6 000 | 2ថ្ងៃ | |
| 31 | | - GPT | 6 000 | 2ថ្ងៃ | |
| 32 | | - Gamma-GT | 6 000 | 2ថ្ងៃ | |
| 33 | | - VDRL (RPR) | 10 000 | 2ថ្ងៃ | |
| 34 | | - TPHA | 10 000 | 2ថ្ងៃ | |
| 35 | | - Malaria Parasite | 6 000 | 2ថ្ងៃ | |
| 36 | | - Widal | 6 000 | 2ថ្ងៃ | |
| 37 | | - Blood Conservation (4Months) | 26 000 | 2ថ្ងៃ | |

| លេខរៀងចំនួនសេវា | បរិយាយ | | តម្លៃឯកតានៃសេវា (រៀល) | រយៈពេលអតិបរមាសម្រាប់ការផ្តល់សេវា (ថ្ងៃធ្វើការ) | សុពលភាព |
|---|---|---|---|---|---|
| | 4.2 | ផ្នែកទី2 : ពិនិត្យទឹកនោម | | | |
| 38 | | - Albumin, Sugar (+Pregnancy Test) | 8 000 | 2ថ្ងៃ | |
| 39 | | - Morphine | 22 000 | 2ថ្ងៃ | |
| 40 | | - Methamphetamine | 22 000 | 2ថ្ងៃ | |
| | 4.3 | ផ្នែកទី3 : ពិនិត្យផ្សេងៗ | | | |
| 41 | | - Hearing Acuity | 30 000 | 2ថ្ងៃ | |
| 42 | | - ECG | 20 000 | 2ថ្ងៃ | |
| 43 | | - Heart Ultra-sound | 60 000 | 2ថ្ងៃ | |
| 44 | 5 | ការបញ្ជាក់លើវិញ្ញាបនបត្រសុខភាពសិក្ខាកាមខ្មែរទៅបរទេសតាមការស្នើសុំ (ក្នុង 1 នាក់) | 20 000 | 1ថ្ងៃ | 6ខែ |
| 45 | 6 | វគ្គបណ្តុះបណ្តាលគ្រូពេទ្យសហគ្រាស និងមន្ត្រីសុវត្ថិភាពការងារ មុនចូលបម្រើការងារតាមសហគ្រាស (ក្នុង 1 នាក់) | 400 000 | 7ថ្ងៃ | អចិន្ត្រៃយ៍ |
| | 7 | ការបណ្តុះបណ្តាលសុខភាព និងសុវត្ថិភាពការងារសម្រាប់និយោជក និងតំណាងកម្មករ និយោជិត (ក្នុង 1 នាក់) | | | |
| 46 | 7.1 | - នៅរាជធានីភ្នំពេញ | 50 000 | 7ថ្ងៃ | អចិន្ត្រៃយ៍ |
| 47 | 7.2 | - នៅតាមបណ្តាខេត្ត | 80 000 | 7ថ្ងៃ | អចិន្ត្រៃយ៍ |
| 48 | 8 | បញ្ជាក់លើវិញ្ញាបនបត្រសុខភាពផ្ទាល់ខ្លួនសម្រាប់ជនបរទេស | 20 000 | 3ថ្ងៃ | 6ខែ |

| លេខរៀង | ចំនួនសេវា | បរិយាយ | តម្លៃឯកតានៃសេវា (រៀល) | រយៈពេលអតិបរមាសម្រាប់ការផ្តល់សេវា (ថ្ងៃធ្វើការ) | សុពលភាព |
|---|---|---|---|---|---|
| 49 | 9 | ផ្តល់វិញ្ញាបនបត្របញ្ជាក់ការវាយតម្លៃហានិភ័យការងារនៅតាមរោងចក្រ សហគ្រាស (តាមការស្នើសុំ) | 2 000 000 | 7ថ្ងៃ | 1ឆ្នាំ |
| 50 | 10 | ការផ្តល់លិខិតអនុញ្ញាតប្រកបមុខរបរជាគ្រូពេទ្យសហគ្រាស | 200 000 | 7ថ្ងៃ | 2ឆ្នាំ |
| II. **សេវាសាធារណៈផ្តល់ដោយនាយកដ្ឋានអធិការកិច្ចការងារ** | | | | | |
| | 11 | ការចុះបញ្ជិកានិងសំណុំបែបបទ ស្តីពីសហគ្រាស គ្រឹះស្ថានដែលមានកម្មករ និយោជិតចាប់ពីចំនួន 01 នាក់ ដល់ 07 នាក់ | | | |
| 51 | 11.1 | - ចុះបញ្ជិកា សេចក្តីប្រកាសជូនដំណឹងបើកសហគ្រាស | 20 000 | 15ថ្ងៃ | 3ឆ្នាំ |
| 52 | 11.2 | - ចុះបញ្ជិកា សៀវភៅបញ្ជីប្រចាំគ្រឹះស្ថាន | 60,000 | 7ថ្ងៃ | អចិន្ត្រៃយ៍ |
| 53 | 11.3 | - ចុះបញ្ជិកា សៀវភៅបើកប្រាក់ | 80,000 | 7ថ្ងៃ | អចិន្ត្រៃយ៍ |
| | 12 | ការចុះបញ្ជិកា និងទិដ្ឋាការសំណុំបែបបទ ស្តីពីសហគ្រាស គ្រឹះស្ថានដែលមានកម្មករ និយោជិតចាប់ពីចំនួន 08 នាក់ ដល់ 100 នាក់ | | | |
| 54 | 12.1 | - ចុះបញ្ជិកា សេចក្តីប្រកាសជូនដំណឹងបើកសហគ្រាស | 30 000 | 15ថ្ងៃ | 3ឆ្នាំ |
| 55 | 12.2 | - ចុះបញ្ជិកា សៀវភៅបញ្ជីប្រចាំគ្រឹះស្ថាន | 60,000 | 7ថ្ងៃ | អចិន្ត្រៃយ៍ |
| 56 | 12.3 | - ចុះបញ្ជិកា សៀវភៅបើកប្រាក់ | 80,000 | 7ថ្ងៃ | អចិន្ត្រៃយ៍ |
| 57 | 12.4 | - ចុះទិដ្ឋាការ បទបញ្ជាផ្ទៃក្នុងរបស់សហគ្រាស | 600 000 | 60ថ្ងៃ | អចិន្ត្រៃយ៍ |
| | 13 | ការចុះបញ្ជិកា និងទិដ្ឋាការសំណុំបែបបទ ស្តីពីសហគ្រាស គ្រឹះស្ថានដែលមានកម្មករ និយោជិតចាប់ពីចំនួន 101 នាក់ ដល់ 500 នាក់ | | | |
| 58 | 13.1 | - ចុះបញ្ជិកា សេចក្តីប្រកាសជូនដំណឹងបើកសហគ្រាស | 100 000 | 15ថ្ងៃ | 3ឆ្នាំ |
| 59 | 13.2 | - ចុះបញ្ជិកា សៀវភៅបញ្ជីប្រចាំគ្រឹះស្ថាន | 80 000 | 7ថ្ងៃ | អចិន្ត្រៃយ៍ |

| លេខរៀងចំនួនសេវា | | បរិយាយ | តម្លៃឯកតានៃសេវា (រៀល) | រយៈពេលអតិបរមាសម្រាប់ការផ្តល់សេវា (ថ្ងៃធ្វើការ) | សុពលភាព |
|---|---|---|---|---|---|
| 60 | 13.3 | - ចុះបញ្ជិកា សៀវភៅបើកប្រាក់ | 120 000 | 7ថ្ងៃ | អចិន្ត្រៃយ៍ |
| 61 | 13.4 | - ចុះទិដ្ឋាការ បទបញ្ជាផ្ទៃក្នុងរបស់សហគ្រាស | 600 000 | 60ថ្ងៃ | អចិន្ត្រៃយ៍ |
| | 14 | ការចុះបញ្ជិកា និងទិដ្ឋាការសំណុំបែបបទ ស្តីពីសហគ្រាស គ្រឹះស្ថានដែលមានកម្មករ និយោជិតចាប់ពីចំនួន 501 នាក់ឡើងទៅ | | | |
| 62 | 14.1 | - ចុះបញ្ជិកា សេចក្តីប្រកាសជូនដំណឹងបើកសហគ្រាស | 200 000 | 15ថ្ងៃ | 3ឆ្នាំ |
| 63 | 14.2 | - ចុះបញ្ជិកា សៀវភៅបញ្ជីប្រចាំគ្រឹះស្ថាន | 80 000 | 7ថ្ងៃ | អចិន្ត្រៃយ៍ |
| 64 | 14.3 | - ចុះបញ្ជិកា សៀវភៅបើកប្រាក់ | 120 000 | 7ថ្ងៃ | អចិន្ត្រៃយ៍ |
| 65 | 14.4 | - ចុះទិដ្ឋាការ បទបញ្ជាផ្ទៃក្នុងរបស់សហគ្រាស | 600 000 | 60ថ្ងៃ | អចិន្ត្រៃយ៍ |
| 66 | 15 | ផ្តល់លិខិតអនុញ្ញាតឱ្យសហគ្រាស-គ្រឹះស្ថានធ្វើការបន្ថែមម៉ោង | 100 000 | 7ថ្ងៃ | 2ខែ |
| 67 | 16 | ផ្តល់លិខិតអនុញ្ញាតឱ្យសហគ្រាស-គ្រឹះស្ថានធ្វើការនៅថ្ងៃឈប់សម្រាក់ប្រចាំសប្តាហ៍ | 100 000 | 7ថ្ងៃ | 1ខែ |
| 68 | 17 | ផ្តល់លិខិតអនុញ្ញាតឱ្យសហគ្រាស-គ្រឹះស្ថានបើកប្រាក់តាមប្រព័ន្ធកុំព្យូទ័រ | 200 000 | 7ថ្ងៃ | អចិន្ត្រៃយ៍ |
| III. **សេវាសាធារណៈផ្តល់ដោយនាយកដ្ឋានវិវាទការងារ** | | | | | |
| | 18 | ការចេញលិខិតទទួលស្គាល់ការបោះឆ្នោតជ្រើសរើសប្រតិភូបុគ្គលិក | | | |
| 69 | 18.1 | - សម្រាប់សហគ្រាសគ្រឹះស្ថានដែលប្រើប្រាស់កម្មករនិយោជិតចាប់ពីចំនួន 08 នាក់ ដល់ 100 នាក់ | 80 000 | 7ថ្ងៃ | ២ឆ្នាំ |
| 70 | 18.2 | - សម្រាប់សហគ្រាសគ្រឹះស្ថានដែលប្រើប្រាស់កម្មករនិយោជិតចាប់ពីចំនួន 101 នាក់ ដល់ 500 នាក់ | 150 000 | 7ថ្ងៃ | ២ឆ្នាំ |
| 71 | 18.3 | - សម្រាប់សហគ្រាសគ្រឹះស្ថានដែលប្រើប្រាស់កម្មករនិយោជិតចាប់ពីចំនួន 501 នាក់ ដល់ 800 នាក់ | 250 000 | 7ថ្ងៃ | ២ឆ្នាំ |
| 72 | 18.4 | - សម្រាប់សហគ្រាសគ្រឹះស្ថានដែលប្រើប្រាស់កម្មករនិយោជិតចាប់ពីចំនួន 801 នាក់ឡើងទៅ | 400 000 | 7ថ្ងៃ | ២ឆ្នាំ |

| លេខរៀងចំនួនសេវា | | បរិយាយ | តម្លៃឯកតានៃសេវា (រៀល) | រយៈពេលអតិបរមាសម្រាប់ការផ្តល់សេវា (ថ្ងៃធ្វើការ) | សុពលភាព |
|---|---|---|---|---|---|
| IV. សេវាសាធារណៈផ្តល់ដោយនាយកដ្ឋានការងារកុមារ | | | | | |
| | 19 | ការចុះបញ្ជិកា និងទិដ្ឋាការសំណុំបែបបទ ស្តីពីសហគ្រាស គ្រឹះស្ថានដែលស្នើសុំប្រើប្រាស់កម្មករនិយោជិតវ័យក្មេងចាប់ពី 01 នាក់ ដល់ 50 នាក់ និងចាប់ពី 51 នាក់ ដល់ 100 នាក់ | | | |
| 73 | 19.1 | ការចុះបញ្ជិកាសៀវភៅចុះនាមក្មេងអាយុពី12ឆ្នាំដល់ក្រោម15ឆ្នាំ | 80 000 | 10ថ្ងៃ | អចិន្ត្រៃយ៍ |
| 74 | 19.2 | ការចុះបញ្ជិកាសៀវភៅចុះនាមក្មេងអាយុពី15ឆ្នាំ ដល់ក្រោម18ឆ្នាំ | 80 000 | 10ថ្ងៃ | អចិន្ត្រៃយ៍ |
| | 19.3 | ផ្តល់ទិដ្ឋាការជូនក្រុមហ៊ុនដែលស្នើសុំប្រើប្រាស់កម្មករនិយោជិតវ័យក្មេង | | | |
| 75 | | - ពី 01 នាក់ ដល់ 07 នាក់ | 200 000 | 20ថ្ងៃ | 1ឆ្នាំ |
| 76 | | - ពី 08 នាក់ ដល់ 50 នាក់ | 600 000 | 20ថ្ងៃ | 1ឆ្នាំ |
| 77 | | - ពី 51 នាក់ ដល់ 100 នាក់ | 800 000 | 20ថ្ងៃ | 1ឆ្នាំ |
| V. សេវាសាធារណៈផ្តល់ដោយនាយកដ្ឋានបណ្តុះបណ្តាល | | | | | |
| 78 | 20 | សំណុំបែបបទហ្វឹកហ្វឺនកូនជាង | 5 000 | 3ថ្ងៃ | 1ឆ្នាំ |
| 79 | 21 | ការផ្តល់ប័ណ្ណទទួលស្គាល់ជំនាញវិជ្ជាជីវៈ | 5 000 | 15ថ្ងៃ ក្រោយបញ្ចប់វគ្គ | អចិន្ត្រៃយ៍ |
| 80 | 22 | ការផ្តល់វិញ្ញាបនបត្រហ្វឹកហ្វឺនកូនជាង | 15 000 | 15ថ្ងៃ ក្រោយបញ្ចប់វគ្គ | អចិន្ត្រៃយ៍ |
| VI. សេវាសាធារណៈផ្តល់ដោយនាយកដ្ឋានគ្រប់គ្រងគ្រឹះស្ថានសិក្សា | | | | | |
| 81 | 23 | ការចុះហត្ថលេខាលើសញ្ញាបត្រសិស្ស-និស្សិតបង់ថ្លៃ | 8 000 | 60ថ្ងៃ | អចិន្ត្រៃយ៍ |

| លេខរៀងចំនួនសេវា | | បរិយាយ | តម្លៃឯកតានៃសេវា (រៀល) | រយៈពេលអតិបរមាសម្រាប់ការផ្តល់សេវា (ថ្ងៃធ្វើការ) | សុពលភាព |
|---|---|---|---|---|---|
| | 24 | ការចុះបញ្ជិកាអនុញ្ញាតបើកគ្រឹះស្ថានអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ ( អបវ ) | | | |
| 82 | 24.1 | កម្រិតវិញ្ញាបនបត្រ (រយៈពេលលើសពី៣ខែ) | 4 000 000 | 30ថ្ងៃ | 6ឆ្នាំ |
| 83 | 24.2 | កម្រិតសញ្ញាបត្រជាន់ខ្ពស់/បរិញ្ញាបត្ររង បច្ចេកទេស/ឯកទេស | 8 000 000 | 60ថ្ងៃ | 6ឆ្នាំ |
| 84 | 24.3 | កម្រិតបរិញ្ញាបត្របច្ចេកវិទ្យា/ឯកទេសសញ្ញាបត្រវិស្វករ | 12 000 000 | 60ថ្ងៃ | 6ឆ្នាំ |
| 85 | 24.4 | កម្រិតបរិញ្ញាបត្រជាន់ខ្ពស់បច្ចេកវិទ្យា/ឯកទេសនិង បណ្ឌិតបច្ចេកវិទ្យា/ឯកទេស | 16 000 000 | 60ថ្ងៃ | 6ឆ្នាំ |
| 86 | 24.5 | បើកសាខា បន្ថែមជំនាញ ឬ ដំឡើងកម្រិតបណ្តុះបណ្តាល | 8 000 000 | 60ថ្ងៃ | 6ឆ្នាំ |
| | 25 | ការសុំបន្តសុពលភាព ការចុះបញ្ជិកាអនុញ្ញាតបើកគ្រឹះស្ថានអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ ( អបវ ) | | | |
| 87 | 25.1 | កម្រិតវិញ្ញាបនបត្រ (រយៈពេលលើសពី៣ខែ) | ឥតគិតថ្លៃ | 30ថ្ងៃ | 6ឆ្នាំ |
| 88 | 25.2 | កម្រិតសញ្ញាបត្រជាន់ខ្ពស់/បរិញ្ញាបត្ររង បច្ចេកទេស/ឯកទេស | ឥតគិតថ្លៃ | 60ថ្ងៃ | 6ឆ្នាំ |
| 89 | 25.3 | កម្រិតបរិញ្ញាបត្របច្ចេកវិទ្យា/ឯកទេសសញ្ញាបត្រវិស្វករ | ឥតគិតថ្លៃ | 60ថ្ងៃ | 6ឆ្នាំ |
| 90 | 25.4 | កម្រិតបរិញ្ញាបត្រជាន់ខ្ពស់បច្ចេកវិទ្យា/ឯកទេសនិង បណ្ឌិតបច្ចេកវិទ្យា/ឯកទេស | ឥតគិតថ្លៃ | 60ថ្ងៃ | 6ឆ្នាំ |
| 91 | 25.5 | បើកសាខា បន្ថែមជំនាញ ឬ ដំឡើងកម្រិតបណ្តុះបណ្តាល | ឥតគិតថ្លៃ | 60ថ្ងៃ | 6ឆ្នាំ |
| **VII. សេវាសាធារណៈផ្តល់ដោយនាយកដ្ឋានស្តង់ដារ និងកម្មវិធីសិក្សា** | | | | | |
| 92 | 26 | ធ្វើតេស្តសមត្ថភាព ផ្នែកសេវាកម្ម កម្រិត1 ឬកម្រិត2 តាមការស្នើសុំ (ក្នុង 1នាក់) | 80 000 | | |
| 93 | 27 | ធ្វើតេស្តសមត្ថភាព ផ្នែកសេវាកម្ម កម្រិត3 ឬកម្រិត4 តាមការស្នើសុំ (ក្នុង 1នាក់) | 100 000 | | |
| 94 | 28 | ធ្វើតេស្តសមត្ថភាព ផ្នែកវិស្វកម្ម កម្រិត1 ឬកម្រិត2 តាមការស្នើសុំ (ក្នុង 1នាក់) | 120 000 | | |

| លេខរៀង | ចំនួនសេវា | បរិយាយ | តម្លៃឯកតានៃសេវា (រៀល) | រយៈពេលអតិបរមាសម្រាប់ការផ្ដល់សេវា (ថ្ងៃធ្វើការ) | សុពលភាព |
|---|---|---|---|---|---|
| 95 | 29 | ធ្វើតេស្តសមត្ថភាព ផ្នែកវិស្វកម្ម កម្រិត3 ឬកម្រិត4 តាមការស្នើសុំ (ក្នុង 1 នាក់) | 150 000 | | |
| 96 | 30 | ការផ្ដល់គុណវុឌ្ឍិ និងចុះបញ្ជិកា តាមការស្នើសុំ (ក្នុង 1 នាក់) | 20 000 | 30ថ្ងៃ ក្រោយប្រកាសលទ្ធផល | 5ឆ្នាំ |
| VIII. សេវាសាធារណៈផ្ដល់ដោយនាយកដ្ឋានមុខរបរ និងហត្ថពលកម្ម | | | | | |
| 97 | 31 | ការចេញលិខិតបញ្ជាក់ (ទុតិយតា) សម្រាប់កម្មករ និយោជិត (ជនកម្ពុជា) | 8 000 | 15ថ្ងៃ | |
| 98 | 32 | ការចេញលិខិតបញ្ជាក់ (ទុតិយតា) សម្រាប់កម្មករ និយោជិត (ជនបរទេស) | 80 000 | 15ថ្ងៃ | |
| 99 | 33 | ការចុះបញ្ជិកាលើកិច្ចសន្យាការងារជនបរទេស (កិច្ចសន្យាការងារដែលមានកំណត់ចិរវេលា មានកាលបរិច្ឆេទចាប់ផ្ដើម និងកាលបរិច្ឆេទបញ្ចប់ត្រឹមត្រូវ និងច្បាស់លាស់) | 40 000 | 15ថ្ងៃ | |
| 100 | 34 | ការផ្ដល់វិញ្ញាបនបត្រលើការគ្រប់គ្រងនិងការបញ្ជូនពលករខ្មែរទៅធ្វើការនៅបរទេសតាមរយៈទីភ្នាក់ងារជ្រើសរើសឯកជន | ឥតគិតថ្លៃ | 15ថ្ងៃ | 5ឆ្នាំ |
| 101 | 35 | ការពន្យាសុពលភាពការអនុញ្ញាតឱ្យបើកទីភ្នាក់ងារជ្រើសរើសឯកជន លើការគ្រប់គ្រង និងការបញ្ជូនពលករខ្មែរទៅធ្វើការនៅបរទេស | 1 500 000 | 15ថ្ងៃ | 5ឆ្នាំ |
| 102 | 36 | ការធ្វើទុតិយតាវិញ្ញាបនបត្រនានា | 80 000 | 20ថ្ងៃ | 5ឆ្នាំ |
| 103 | 37 | ការអនុញ្ញាតឱ្យបើកទីភ្នាក់ងារឯកជនផ្ដល់សេវារកការងារឱ្យធ្វើក្នុងស្រុក | 1 000 000 | 20ថ្ងៃ | 5ឆ្នាំ |
| 104 | 38 | ការពន្យាសុពលភាពការអនុញ្ញាតឱ្យបើកទីភ្នាក់ងារឯកជនផ្ដល់សេវារកការងារឱ្យធ្វើក្នុងស្រុក | 800 000 | 20ថ្ងៃ | 5ឆ្នាំ |

| លេខរៀង | ចំនួនសេវា | បរិយាយ | តម្លៃឯកតានៃសេវា (រៀល) | រយៈពេលអតិបរមាសម្រាប់ការផ្តល់សេវា (ថ្ងៃធ្វើការ) | សុពលភាព |
|---|---|---|---|---|---|
| 105 | 39 | ការផ្តល់ប័ណ្ណការងារ និងសៀវភៅការងាររបស់ជនកម្ពុជា | 10 000 | 20 ថ្ងៃ | អចិន្ត្រៃយ៍ |
| 106 | 40 | **ការផ្តល់ប័ណ្ណការងារ និងសៀវភៅការងាររបស់ជនបរទេស** | **520 000** | 20 ថ្ងៃ | 1ឆ្នាំ |
| | | ចំណូលថវិកាជាតិ | 405 000 | | |
| | | តម្លៃទូទាត់ជូនក្រុមហ៊ុន អ៊ី-សឹលូសិន (ខេមបូឌា) យោងតាមកិច្ចសន្យា ឬ កិច្ចព្រមព្រៀង | 115 000 | | |
| 107 | 41 | **ការផ្តល់ប័ណ្ណការងារនិងសៀវភៅការងាររបស់ជនបរទេស (ជនបរទេសស្នាក់នៅអចិន្ត្រៃយ៍)** | **360 000** | 20 ថ្ងៃ | 1ឆ្នាំ |
| | | ចំណូលថវិកាជាតិ | 245 000 | | |
| | | តម្លៃទូទាត់ជូនក្រុមហ៊ុន អ៊ី-សឹលូសិន (ខេមបូឌា) យោងតាមកិច្ចសន្យា ឬ កិច្ចព្រមព្រៀង | 115 000 | | |
| 108 | 42 | **ការផ្តល់កូតាប្រើប្រាស់ជនបរទេសប្រចាំឆ្នាំសម្រាប់សហគ្រាស គ្រឹះស្ថាននីមួយៗ** | **200 000** | 20 ថ្ងៃ | 1ឆ្នាំ |
| | | ចំណូលថវិកាជាតិ | 85 000 | | |
| | | តម្លៃទូទាត់ជូនក្រុមហ៊ុន អ៊ី-សឹលូសិន (ខេមបូឌា) យោងតាមកិច្ចសន្យា ឬ កិច្ចព្រមព្រៀង | 115 000 | | |

# ឧបសម្ព័ន្ធ២

## ការផ្តល់សេវាសាធារណៈដោយមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈរាជធានី ខេត្ត

## ភ្ជាប់នឹងប្រកាសអន្តរក្រសួងលេខ ៧១៤ សហវ.ប្រក ចុះថ្ងៃទី ១៩ ខែ កក្កដា ឆ្នាំ២០១៨

| លេខរៀងចំនួនសេវា | | បរិយាយ | តម្លៃឯកតានៃសេវា (រៀល) | រយៈពេលអតិបរមាសម្រាប់ការផ្តល់សេវា (ថ្ងៃធ្វើការ) | សុពលភាព |
|---|---|---|---|---|---|
| | 1 | ការចុះបញ្ជិកានិងសំណុំបែបបទ ស្តីពីសហគ្រាស គ្រឹះស្ថានដែលមានកម្មករ និយោជិតចាប់ពីចំនួន 01 នាក់ ដល់ 07 នាក់ | | | |
| 1 | 1.1 | - ចុះបញ្ជិកា សេចក្តីប្រកាសជូនដំណឹងបើកសហគ្រាស | 20 000 | 15ថ្ងៃ | 3ឆ្នាំ |
| 2 | 1.2 | - ចុះបញ្ជិកា សៀវភៅបញ្ជីប្រចាំគ្រឹះស្ថាន | 60,000 | 7ថ្ងៃ | អចិន្ត្រៃយ៍ |
| 3 | 1.3 | - ចុះបញ្ជិកា សៀវភៅបើកប្រាក់ | 80,000 | 7ថ្ងៃ | អចិន្ត្រៃយ៍ |
| | 2 | ការចុះបញ្ជិកា និងទិដ្ឋាការសំណុំបែបបទ ស្តីពីសហគ្រាស គ្រឹះស្ថានដែលមានកម្មករ និយោជិតចាប់ពីចំនួន 08 នាក់ ដល់ 100 នាក់ | | | |
| 4 | 2.1 | - ចុះបញ្ជិកា សេចក្តីប្រកាសជូនដំណឹងបើកសហគ្រាស | 30 000 | 15ថ្ងៃ | 3ឆ្នាំ |
| 5 | 2.2 | - ចុះបញ្ជិកា សៀវភៅបញ្ជីប្រចាំគ្រឹះស្ថាន | 60,000 | 7ថ្ងៃ | អចិន្ត្រៃយ៍ |
| 6 | 2.3 | - ចុះបញ្ជិកា សៀវភៅបើកប្រាក់ | 80,000 | 7ថ្ងៃ | អចិន្ត្រៃយ៍ |
| 7 | 2.4 | - ចុះទិដ្ឋាការ បទបញ្ជាផ្ទៃក្នុងរបស់សហគ្រាស | 600 000 | 60ថ្ងៃ | អចិន្ត្រៃយ៍ |
| | 3 | ការចុះបញ្ជិកា និងទិដ្ឋាការសំណុំបែបបទ ស្តីពីសហគ្រាស គ្រឹះស្ថានដែលមានកម្មករ និយោជិតចាប់ពីចំនួន 101 នាក់ ដល់ 500 នាក់ | | | |
| 8 | 3.1 | - ចុះបញ្ជិកា សេចក្តីប្រកាសជូនដំណឹងបើកសហគ្រាស | 100 000 | 15ថ្ងៃ | 3ឆ្នាំ |
| 9 | 3.2 | - ចុះបញ្ជិកា សៀវភៅបញ្ជីប្រចាំគ្រឹះស្ថាន | 80 000 | 7ថ្ងៃ | អចិន្ត្រៃយ៍ |

| លេខរៀង ចំនួនសេវា | បរិយាយ | | តម្លៃឯកតា នៃសេវា (រៀល) | រយៈពេលអតិបរមាសម្រាប់ការផ្តល់សេវា (ថ្ងៃធ្វើការ) | សុពលភាព |
|---|---|---|---|---|---|
| 10 | 3.3 | - ចុះបញ្ជិកា សៀវភៅបើកប្រាក់ | 120 000 | 7ថ្ងៃ | អចិន្ត្រៃយ៍ |
| 11 | 3.4 | - ចុះទិដ្ឋាការ បទបញ្ជាផ្ទៃក្នុងរបស់សហគ្រាស | 600 000 | 60ថ្ងៃ | អចិន្ត្រៃយ៍ |
| | 4 | ការចុះបញ្ជិកា និងទិដ្ឋាការសំណុំបែបបទ ស្តីពីសហគ្រាស គ្រឹះស្ថានដែលមានកម្មករ និយោជិតចាប់ពីចំនួន 501 នាក់ឡើងទៅ | | | |
| 12 | 4.1 | - ចុះបញ្ជិកា សេចក្តីប្រកាសជូនដំណឹងបើកសហគ្រាស | 200 000 | 15ថ្ងៃ | 3ឆ្នាំ |
| 13 | 4.2 | - ចុះបញ្ជិកា សៀវភៅបញ្ជីប្រចាំគ្រឹះស្ថាន | 80 000 | 7ថ្ងៃ | អចិន្ត្រៃយ៍ |
| 14 | 4.3 | - ចុះបញ្ជិកា សៀវភៅបើកប្រាក់ | 120 000 | 7ថ្ងៃ | អចិន្ត្រៃយ៍ |
| 15 | 4.4 | - ចុះទិដ្ឋាការ បទបញ្ជាផ្ទៃក្នុងរបស់សហគ្រាស | 600 000 | 60ថ្ងៃ | អចិន្ត្រៃយ៍ |
| 16 | 5 | ផ្តល់លិខិតអនុញ្ញាតឱ្យសហគ្រាស-គ្រឹះស្ថានធ្វើការបន្ថែមម៉ោង | 100 000 | 7ថ្ងៃ | 2ខែ |
| 17 | 6 | ផ្តល់លិខិតអនុញ្ញាតឱ្យសហគ្រាស-គ្រឹះស្ថានធ្វើការនៅថ្ងៃឈប់សម្រាកប្រចាំសប្តាហ៍ | 100 000 | 7ថ្ងៃ | 1ខែ |
| 18 | 7 | ផ្តល់លិខិតអនុញ្ញាតឱ្យសហគ្រាស-គ្រឹះស្ថានបើកប្រាក់តាមប្រព័ន្ធកុំព្យូទ័រ | 200 000 | 7ថ្ងៃ | អចិន្ត្រៃយ៍ |
| | 8 | ការចេញលិខិតទទួលស្គាល់ការបោះឆ្នោតជ្រើសរើសប្រតិភូបុគ្គលិក | | | |
| 19 | 8.1 | - សម្រាប់សហគ្រាសគ្រឹះស្ថានដែលប្រើប្រាស់កម្មករនិយោជិតចាប់ពីចំនួន 08 នាក់ ដល់ 100 នាក់ | 80 000 | 7ថ្ងៃ | ២ឆ្នាំ |
| 20 | 8.2 | - សម្រាប់សហគ្រាសគ្រឹះស្ថានដែលប្រើប្រាស់កម្មករនិយោជិតចាប់ពីចំនួន 101 នាក់ ដល់ 500 នាក់ | 150 000 | 7ថ្ងៃ | ២ឆ្នាំ |
| 21 | 8.3 | - សម្រាប់សហគ្រាសគ្រឹះស្ថានដែលប្រើប្រាស់កម្មករនិយោជិតចាប់ពីចំនួន 501 នាក់ ដល់ 800 នាក់ | 250 000 | 7ថ្ងៃ | ២ឆ្នាំ |
| 22 | 8.4 | - សម្រាប់សហគ្រាសគ្រឹះស្ថានដែលប្រើប្រាស់កម្មករនិយោជិតចាប់ពីចំនួន 801 នាក់ឡើងទៅ | 400 000 | 7ថ្ងៃ | ២ឆ្នាំ |
| 23 | 9 | សំណុំបែបបទហ្វឹកហ្វឺនកូនជាង | 5 000 | 3ថ្ងៃ | 1ឆ្នាំ |
| 24 | 10 | ការផ្តល់ប័ណ្ណទទួលស្គាល់ជំនាញវិជ្ជាជីវៈ | 5 000 | 15ថ្ងៃ ក្រោយបញ្ចប់វគ្គ | អចិន្ត្រៃយ៍ |

| លេខរៀង | ចំនួនសេវា | បរិយាយ | តម្លៃឯកតានៃសេវា (រៀល) | រយៈពេលអតិបរមាសម្រាប់ការផ្តល់សេវា (ថ្ងៃធ្វើការ) | សុពលភាព |
|---|---|---|---|---|---|
| 25 | 11 | ការផ្តល់វិញ្ញាបនបត្រហ្វឹកហ្វឺនកូនជាង | 15 000 | 15ថ្ងៃ ក្រោយបញ្ចប់វគ្គ | អចិន្ត្រៃយ៍ |
| 26 | 12 | ការចុះបញ្ជិកាអនុញ្ញាតបើកគ្រឹះស្ថានអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ ( អបវ )កម្រិតវិញ្ញាបនបត្រ (រយៈពេលចាប់ពី៣ខែចុះ) | 2 000 000 | 30ថ្ងៃ | 6ឆ្នាំ |
| 27 | 13 | ការបន្តសុពលភាព ការចុះបញ្ជិកាអនុញ្ញាតបើកគ្រឹះស្ថានអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ ( អបវ ) កម្រិតវិញ្ញាបនបត្រ (រយៈពេលចាប់ពី៣ខែចុះ) | ឥតគិតថ្លៃ | 30ថ្ងៃ | 6ឆ្នាំ |
| 28 | 14 | ការចេញលិខិតបញ្ជាក់ (ទុតិយតា) សម្រាប់កម្មករ និយោជិត (ជនកម្ពុជា) | 8 000 | 15ថ្ងៃ | |
| 29 | 15 | ការចេញលិខិតបញ្ជាក់ (ទុតិយតា) សម្រាប់កម្មករ និយោជិត (ជនបរទេស) | 80 000 | 15ថ្ងៃ | |
| 30 | 16 | ការចុះបញ្ជិកាលើកិច្ចសន្យាការងារជនបរទេស (កិច្ចសន្យាការងារដែលមានកំណត់ថិរវេលា មានកាលបរិច្ឆេទចាប់ផ្តើម និងកាលបរិច្ឆេទបញ្ចប់ត្រឹមត្រូវ និងច្បាស់លាស់) | 40 000 | 15ថ្ងៃ | |
| 31 | 17 | ការផ្តល់ប័ណ្ណការងារ និងសៀវភៅការងាររបស់ជនកម្ពុជា | 10 000 | 20 ថ្ងៃ | អចិន្ត្រៃយ៍ |
| 32 | 18 | **ការផ្តល់ប័ណ្ណការងារ និងសៀវភៅការងាររបស់ជនបរទេស** | **520 000** | **20 ថ្ងៃ** | **1ឆ្នាំ** |
| | | ចំណូលថវិកាជាតិ | 405 000 | | |
| | | តម្លៃទូទាត់ជូនក្រុមហ៊ុន អ៊ី-សឺលូសិន (ខេមបូឌា) យោងតាមកិច្ចសន្យា ឬ កិច្ចព្រមព្រៀង | 115 000 | | |
| 33 | 19 | **ការផ្តល់ប័ណ្ណការងារ និងសៀវភៅការងាររបស់ជនបរទេស (តំបន់អភិវឌ្ឍន៍ត្រីកោណ)** | **440 000** | **20 ថ្ងៃ** | **1ឆ្នាំ** |
| | | ចំណូលថវិកាជាតិ | 325 000 | | |
| | | តម្លៃទូទាត់ជូនក្រុមហ៊ុន អ៊ី-សឺលូសិន (ខេមបូឌា) យោងតាមកិច្ចសន្យា ឬ កិច្ចព្រមព្រៀង | 115 000 | | |

| លេខរៀង | ចំនួនសេវា | បរិយាយ | តម្លៃឯកតា នៃសេវា (រៀល) | រយៈពេលអតិបរមាសម្រាប់ការផ្តល់សេវា (ថ្ងៃធ្វើការ) | សុពលភាព |
|---|---|---|---|---|---|
| 34 | 20 | ការផ្តល់ប័ណ្ណការងារនិងសៀវភៅការងាររបស់ជនបរទេស (ជនបរទេសស្នាក់នៅអចិន្ត្រៃយ៍) | 360 000 | 20 ថ្ងៃ | 1ឆ្នាំ |
| | | ចំណូលថវិកាជាតិ | 245 000 | | |
| | | តម្លៃទូទាត់ជូនក្រុមហ៊ុន អ៊ី-សឹលូសិន (ខេមបូឌា) យោងតាមកិច្ចសន្យា ឬ កិច្ចព្រមព្រៀង | 115 000 | | |
| 35 | 21 | ការផ្តល់កូតាប្រើប្រាស់ជនបរទេសប្រចាំឆ្នាំសម្រាប់សហគ្រាស គ្រឹះស្ថាននីមួយៗ | 200 000 | 20 ថ្ងៃ | 1ឆ្នាំ |
| | | ចំណូលថវិកាជាតិ | 85 000 | | |
| | | តម្លៃទូទាត់ជូនក្រុមហ៊ុន អ៊ី-សឹលូសិន (ខេមបូឌា) យោងតាមកិច្ចសន្យា ឬ កិច្ចព្រមព្រៀង | 115 000 | | |